ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ ភ្នំពេញ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៦៧២
ចុះថ្ងៃទី:០៩-០៧-០៧
សាលដីកា
លេខ : ៦៧ "ខ"
ចុះថ្ងៃទី ២៦-០៥-០៩

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០០៩ ដោយមានសមាសភាពដូចខាងក្រោម

<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted]

<u>ក្រឡាបញ្ជី</u>

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៦៧២ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៧ ដែលមាន :

១. ជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស អាយុ ៤៦ឆ្នាំ ជាតិខ្មែរ មុខរបររត់តាក់ស៊ី កើតនៅ ភូមិវត្តកណ្តាល ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង ។ ទីលំនៅសព្វថ្ងៃ ភូមិនរា ឃុំនរា ស្រុកសង្កែ ខេត្តបាត់ដំបង ឪពុកឈ្មោ[redacted]ស) ម្តាយឈ្មោះ[redacted]( ស ) ប្រព[redacted]មានកូន ០៥នាក់ ទោសពីមុនគ្មាន បច្ចុប្បន្ននៅក្រៅឃុំ ។

២. ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ៤១ឆ្នាំ ជាតិឥស្លាម កើតនៅភូមិនរា ឃុំនរា ស្រុកសង្កែ ខេត្តបាត់ដំបង ។ ទីលំនៅសព្វថ្ងៃ ភូមិនរា ឃុំនរា ស្រុកសង្កែ ខេត្តបាត់ដំបង ប្តីឈ្មោ[redacted]ឪពុកឈ្មោះ [redacted]ស) ម្តាយឈ្មោះ [redacted] )ទោសពីមុនមាន ទោសព្យួរ ១០ខែ បច្ចុប្បន្ននៅក្រៅឃុំ ។

៣. ជនជាប់ចោទឈ្មោ[redacted]ភេទស្រី អាយុ ១៨ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ កើតនៅភូមិផ្កាស្លា ឃុំចំការសំរោង ទីរួមខេត្តបាត់ដំបង ។ ទីលំនៅសព្វថ្ងៃ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ឪពុកឈ្មោះ[redacted]ម្តាយឈ្មោ[redacted])នៅលីវ ទោសពីមុនគ្មាន បច្ចុប្បន្ននៅក្រៅឃុំ ។

៤. ជនជាប់ចោទឈ្មោ[redacted]ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបរ រៀនកែសម្ផស្ស កើតនៅ ភូមិចំការសំរោង ឃុំចំការសំរោង ទីរួមខេត្តបាត់ដំបង។ ទីលំនៅសព្វថ្ងៃ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ឪពុកឈ្មោ[redacted](ស) ម្តាយឈ្មោះ[redacted]ស) នៅលីវ ទោសពីមុនគ្មាន ។

៥.ជនជាប់ចោទឈ្មោះ [redacted] ហៅ ពៅ ភេទស្រី អាយុ ៣២ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអូចារ ឃុំជ្រៃ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ ទីលំនៅសព្វថ្ងៃ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted]ម្តាយឈ្មោះ[redacted]) ប្តីឈ្មោះ[redacted]មានកូន០៣នាក់ ទោសពីមុនគ្មាន បច្ចុប្បន្ននៅក្រៅឃុំ ។



Scanned by CamScanner

**<u>ត្រូវចោទពីបទ:</u>** " បង្ករបួសស្នាមដោយចេតនាមានរការទុច " ប្រព្រឹត្តនៅ ភូមិចំការសំរោង ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃ ០៩-០៩-២០០៤ តាមមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

១. [redacted] ហៅ [redacted] ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរ ជាងមាស និងរត់ម៉ូតូឌុប កើតនៅភូមិផ្កាស្លា ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ឪពុកឈ្មោ[redacted]) ម្តាយឈ្មោ[redacted]រ) ប្រពន្ធឈ្មោ[redacted]នកូន៣នាក់ ទោសពីមុនគ្មាន បច្ចុប្បន្ននៅក្រៅឃុំ

២. [redacted] ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ មុខរបរ ជាងម៉ាស៊ីន កើតនៅភូមិផ្កាស្លា ឃុំចំការសំរោង ទីរួមខេត្តបាត់ដំបង។ ទីលំនៅសព្វថ្ងៃ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ឪពុក ឈ្មោ[redacted] (ស) ម្តាយឈ្មោ[redacted]នៅរស់ ទោសពីមុនគ្មាន បច្ចុប្បន្ននៅក្រៅឃុំ ។

៣. [redacted] ភេទស្រី ជាតិខ្មែរឥស្លាម មុខរបរគ្មាន កើតនៅភូមិនរា ឃុំនរា ស្រុកសង្កែ ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃ ភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ឪពុក[redacted]) ម្តាយឈ្មោ[redacted]) នៅរស់ ទោសពីមុនគ្មាន បច្ចុប្បន្ននៅក្រៅឃុំ ។

៤. [redacted] ភេទស្រី អាយុ១៩ឆ្នាំ ជាតិខ្មែរ មុខរបរ លក់គ្រឿងក្លែម កើតនៅភូមិព្រៃដាច់ ឃុំ អូរតាគី ស្រុកបាត់ដំបង ខេត្តបាត់ដំបង។ ទីលំនៅសព្វថ្ងៃ ភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (រ) ម្តាយ[redacted]រ) នៅរស់ ទោសពីមុនគ្មាន បច្ចុប្បន្ននៅក្រៅឃុំ ។

៥. [redacted] ភេទស្រី អាយុ១៩ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរ គ្មាន កើតនៅភូមិនរា ឃុំនរា ស្រុកបាត់ដំបង ខេត្តបាត់ដំបង។ ទីលំនៅសព្វថ្ងៃ ភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង។

**<u>ត្រូវចោទពីបទ</u>** " បង្ករបួសដោយចេតនាមានរការទុច និង ជេរប្រមាថ " ប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃ០៩-០៩-២០០៤ មាត្រា ៤១. ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា ៨ នៃច្បាប់ស្តីពីទមូន់ទោស ។

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ**[redacted]តំណាងគ្រួសារ ។

- តាមបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៥-០៤-២០០៧ របស់ឈ្មោះ ស៊ឹម វ៉ា ប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ ៤២ "យ" ចុះថ្ងៃទី ១១-០៤-២០០៧ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំណុច ទី ២ "ក" និងចំនុចទី ៤ នៃសាលក្រម ។

**<u>ដំណើររឿងហេតុទាំងនេះ</u>**

កាលពីថ្ងៃទី ០៩-០៩-២០០៤ ម៉ោង ២២:៣០នាទី នៅចំណុចវាលស្រែ ១០០០ ភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង មានការជេរប្រមាថវាយតប់គ្នា រវាងគ្រួសារ[redacted]ប្រពន្ធ ឈ្មោ[redacted]កូនស្រី [redacted] និងអ្នកផ្សេងទៀតម្ចាស់ហាងលក់គ្រឿងក្លែម និងខាក់អូខេ (អំពិលទឹកផ្អែម) ជាមួយគ្រួសារ[redacted] ហៅ[redacted] ប្រពន្ធ [redacted]ហៅពៅ. ក្មួយ [redacted] [redacted] ហៅ [redacted]. [redacted] នៅក្នុងផ្ទះ [redacted] លក់គ្រឿងក្លែមទល់មុខគ្នា ។

- **បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៤២"យ" ចុះថ្ងៃទី ១១-០៤-២០០៧ របស់តុលាការ ខេត្តបាត់ដំបង ដែលមានខ្លឹមសារ និង សេចក្តីសំរេចដូចតទៅ :**



Scanned by CamScanner

៣/៣

១. ឱ្យជនជាប់ចោទឈ្មោះ:

ក [redacted] ភេទប្រុស អាយុ ៤៦ឆ្នាំ សញ្ជាតិខ្មែរ

ខ. [redacted] ភេទស្រី អាយុ ៤១ឆ្នាំ សញ្ជាតិខ្មែរ

គ. [redacted] ភេទស្រី អាយុ ២២ឆ្នាំ សញ្ជាតិខ្មែរ

ឃ. [redacted] ភេទស្រី អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ

ង. [redacted] ហៅ [redacted] ភេទស្រី អាយុ៣២ឆ្នាំ សញ្ជាតិខ្មែរ

រួចផុតពីបទ " ជេរប្រមាថ " ប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០០៤ ។

បទល្មើសច្បាប់ព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិអោយផ្តន្ទាទោសតាមមាត្រា ៦៣នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ២៨៦ ដសសព ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ព្រះរាជអាជ្ញាអមតុលាការ ខេត្តបាត់ដំបង និងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ១០៣២ ពសព្រទ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ចៅក្រម ស៊ើបអង្កេតនៃតុលាការខេត្តបាត់ដំបង។ តាមមាត្រា ៣៨ វាក្យខ័ណ្ឌ ៧ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

២. ផ្តន្ទាទោសលើជនជាប់ចោទ :

ក. [redacted] ភេទស្រី អាយុ៤១ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ខែ (បីខែគត់) និងកែប្រែទោស ព្យួរ១០ខែ (ដប់ខែ) តាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៤០ "ច" ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០០៤ របស់តុលាការ ខេត្តបាត់ដំបងទៅជាទោសដាក់ពន្ធនាគារ ។

សរុបទោស គឺដាក់ពន្ធនាគារសរុប ១៣ខែ (ដប់បីខែ) គិតពីថ្ងៃទទួលរងទោសក្នុងពន្ធនាគារ ។

ខ. [redacted] ភេទប្រុស អាយុ៤៦ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់៦ខែ(ប្រាំមួយខែ) ប៉ុន្តែទោសនេះត្រូវព្យួរ

គ. [redacted] ភេទស្រី អាយុ២២ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់៤ខែ (បួនខែគត់) ប៉ុន្តែទោស នេះត្រូវព្យួរ ។

ឃ. [redacted] ភេទស្រី អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ខែ (បីខែគត់) ប៉ុន្តែទោសនេះ ត្រូវព្យួរ ។

ង. [redacted] ហៅ [redacted] ភេទស្រី អាយុ ៣២ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៤ខែ (បួនខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ ។

រយៈពេលសាកល្បង ០៥ឆ្នាំគត់ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។ ពីបទ " បង្ករបួសដោយចេតនា មានអាវុធ "

៣. ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ

ក. [redacted] ហៅ [redacted] ភេទប្រុស អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារសរុប ០៦ខែ (ប្រាំមួយខែគត់ ) ប៉ុន្តែ ទោសនេះត្រូវព្យួរ ។

ខ [redacted] ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៤ខែ (បួនខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ ។

គ [redacted] ភេទស្រី អាយុ២២ឆ្នាំ សញ្ជាតិខ្មែរឥស្លាម ដាក់ពន្ធនាគារសរុប៤ខែ(បួនខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ ។

ឃ. [redacted] ភេទស្រី អាយុ១៩ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់៣ខែ(បីខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ ។

ង. [redacted] ភេទស្រី អាយុ១៩ឆ្នាំ សញ្ជាតិខ្មែរឥស្លាម ដាក់ពន្ធនាគារសរុប៣ខែ(បីខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ ។



Scanned by CamScanner

រយៈពេលសាកល្បង៥ឆ្នាំគត់ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ។ ពីបទ " បង្ករបួសដោយចេតនាមានអាវុធ និងជេរប្រមាថ " ប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី៩-៥-២០០៤ ។

បទល្មើសច្បាប់ព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤១. ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា ៨ នៃច្បាប់ស្តីពីស្ថានទំងន់ទោសក្នុងបទឧក្រិដ្ឋ ។

៤. បង្គាប់អោយជនជាប់ចោទឈ្មោះ [redacted] រួមគ្នាសងថ្លៃព្យាបាលរបួស និង ជម្ងឺចិត្តសរុប ២ 000 000៛ ( ពីរលានរៀល ) ទៅអោយនា [redacted] សំណូមពរលើសពីនេះត្រូវបដិសេធចោល ។

៥. ពេលសាលក្រមចូលជាស្ថាពរ បើជនជាប់ចោទឈ្មោះ [redacted] រឹងរូសពុំព្រម បង់ប្រាក់សំណង ចំនួន ២ 000 000៛ (ពីរលានរៀល) ទៅអោយដើមបណ្តឹងឈ្មោ[redacted]ទនោះ ត្រូវដាក់គុកបង្ខំដល់រូបរាងកាយក្នុង ម្នាក់១ ២ឆ្នាំ ដើម្បីបង្ខំទារប្រាក់ធនទណ្ឌតាមមាត្រា ០៧ និង ០៨ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៦. សាលក្រមនេះជំនុំជម្រះ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] កំបាំងមុខជនជាប់ចោទ[redacted] ។ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៥-០៤-២០០៧ របស់ឈ្មោ[redacted]សុំប្តឹងឧទ្ធរណ៍ និងសាលក្រមលេខ ៤២ "ឃ" ចុះថ្ងៃទី ១១-០៤-២០០៧ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំនុច២ "ក" និងចំនុច៤ នៃសាលក្រម ។

- បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍

- បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍

## **នាពេលសវនាការ**

ប្រធានក្រុមប្រឹក្សាលង្ខេបអង្គហេតុរឿងជូនអង្គសវនាការ

- ឈ្មោ[redacted]ឆ្លើយថា ខ្លួនមិនសុខចិត្តព្រោះវាយគ្នាទៅវាយមក បង្ករបួសទាំងអស់គ្នា ប្រព[redacted]អ្នកកាន់ បំពង់ទីបវាយខ្លួន ខ្លួនចាប់បានស្រែកអោយមេភូមិជួយតែគេមិនជួយទេ ខ្លួនអត់បានវៃគេទេ ខ្លួនបានទៅចាប់ដំបងទីបពិតប្រាកដ មែន ពេលខ្លួនចាប់បំពង់ទីបបាន លើកឡើងលើហើយចោលទៅលើដំបូលផ្ទះ អត់មានត្រូវចំនរណាទេ ។

- ឈ្មោះ [redacted] ឆ្លើយថា តាមពិតប្តីរបស់គាត់ជេរខ្លួន ពេលខ្លួនកំពុងញ៉ាំបាយក្នុងផ្ទះ ខ្លួនក៏ចេញមកហើយក៏បាន ប្រកែកគ្នា។ ចំពោះដំបងទីបខ្លួនឃើញគាត់កាន់ ហើយគាត់បានយកបំពង់ទីបវាយក្បាលខ្លួនរហូតសន្លប់ និង វាយប្រពន្ធខ្លួនត្រូវ ក្បាល. ភ្នែក រហូតដេកពេទ្យ ០៣ខែ ។

## **សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ**

អង្គហេតុបានបញ្ជាក់ថា មានការបង្ករបួសស្នាមទៅវិញទៅមក ហើយជនជាប់ចោទឈ្មោ[redacted]ប្តឹងឧទ្ធរណ៍ទៅនឹង សាលក្រម តុលាការថ្នាក់ក្រោមត្រង់ចំណុច ២ក និង ចំណុច៤ ។

សាលក្រមព្រហ្មទណ្ឌលេខ ៤២ "ឃ" ចុះថ្ងៃទី១១-០៤-២០០៧ បានសំរេចលើករណីរបស់ឈ្មោ[redacted]ដោយដាក់ គុក០៣ខែ (បីខែ) ពីបទ បង្ករបួសស្នាម ថ្ងៃទី០៩-០៥-២០០៤ រួចកែប្រែទោសព្យួរ ក្នុងសាលក្រមព្រហ្មទណ្ឌលេខ ៤០ ចុះថ្ងៃទី១៩-០៧-២០០៤ ពី ១០(ដប់)ខែព្យួរ មក១០(ដប់)ខែគុកវិញនោះ ជាការភន្តច្រឡំដ៏ធ្ងន់ធ្ងរដែលតប្បីសភាព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ បដិសេធសាលក្រមព្រហ្មទណ្ឌនេះចោល ត្រង់ចំណុច២ក រួចកែតម្រូវឡើងវិញដោយចាត់ទុកថា ការប្រព្រឹត្តរបស់



Scanned by CamScanner

ឈ្មោះ[redacted]ជាការមិនរាងចាល ប្រព្រឹត្តច្រំដែល ដែលគប្បីដាក់ទោសតុកតាមស្ថានទម្ងន់វិញ ។

ការប្តឹងឧទ្ធរណ៍ពីសំណាងរដ្ឋប្បវេណីត្រង់ចំណុច ៤ នៃសាលក្រម មហាអយ្យការសូមអោយ សភាព្រហ្មទណ្ឌសំរេចតាមមាត្រា ៣៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌតទៅ ។

**សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា**

១- បណ្តឹងឧទ្ធរណ៍លេខ៨៤ ចុះថ្ងៃទី២៥-០៤-២០០៧ របស់ជនជាប់ចោទឈ្មោះ[redacted]ធ្វើឡើងនៅក្នុងកំណត់ច្បាប់.

២- ជនជាប់ចោទប្តឹងឧទ្ធរណ៍តែលើចំនុចទី២ក និងទី៤ ដូច្នេះ សាលាឧទ្ធរណ៍មិនពិចារណាចំណុចផ្សេងទៀតទេ.

៣- តាមចម្លើយជនជាប់ចោទថា កាលពីថ្ងៃកើតហេតុ ថ្ងៃទី០៩-០៩-២០០៤ ខ្លួនឮសូរឈ្លោះគ្នា ខ្លួនចេញមកមើលឃើញ ប្តីខ្លួន[redacted]ប្រទល់មុខនឹងឈ្មោះ[redacted]ដែកគ្នាស្រាប់តែឈ្មោះ[redacted]ដំបងបំពង់ទីបវាយប្តីខ្លួន តែខ្លួនចាប់ជាប់ស្រាប់តែពៅវាយខ្លួនត្រូវខ្នង ក៏ប្រតាយប្រតប់គ្នា. ខ្លួនអត់បានវាយគេទេ.

ប៉ុន្តែតាមចម្លើយជនជាប់ចោទឈ្មោះ[redacted]ជាកូនចិញ្ចឹមរបស់ជនជាប់ចោទថា ជនជាប់ចោទបានចាប់យកទីបដែលឈ្មោះ[redacted]ប៉ុរុងវាយក្បាលចាំ[redacted]ជាប្តីជនជាប់ចោទ[redacted]) គប់ចោល ក៏ប្រតាយប្រតប់គ្នាឡើង ។

៤- តាមចម្លើយឈ្មោះ[redacted]ថា ជនជាប់ចោទ បានយកបំពង់ទីបវាយក្បាលខ្លួនហើយបោង ។

៥- មានពិរុទ្ធលើជនជាប់ចោទពីបទ " បង្ករបួសស្នាម " ប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៩-០៩-២០០៤ តាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៦- ជនជាប់ចោទត្រូវបានសាលាដំបូងខេត្តបាត់ដំបង សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ១០ខែ ព្យួរ តាមសាលក្រមព្រហ្មទណ្ឌលេខ ៤០"ច" ចុះថ្ងៃទី ១៩-០៧-២០០៤ ហើយមិនរាងចាល ទើបប្រែទៅជាទណ្ឌកម្មអនុវត្ត ក្នុងពន្ធនាគារវិញ.

៧- សាលក្រមព្រហ្មទណ្ឌលេខ ៤២"ឃ" ចុះថ្ងៃទី១១-០៤-២០០៧ របស់សាលាដំបូងខេត្តបាត់ដំបង សម្រេចត្រឹមត្រូវតាម ច្បាប់ គួរតម្កល់ទុកជាបានការ តែគួរលុបវិធានអនុវត្ត ។

**<u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>**

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ៨៤ ចុះថ្ងៃទី២៥-០៤-២០០៧ របស់ជនជាប់[redacted]ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់.

២.តម្កល់ចំណុចទី ២"ក" និង ទី៤ នៃសាលក្រមព្រហ្មទណ្ឌលេខ ៤២ "ឃ" ចុះថ្ងៃទី ១១-០៤-២០០៧ ទុកជាបានការដដែល.

- លុបវិធានអនុវត្តចេញពីការប្រកាសនៃសាលក្រម.

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹង បើកផ្លូវសារទុក្ខ ០១ខែ គិតចាប់ពីពេលនេះតទៅ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |



Scanned by CamScanner

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ ២០០៩

ក្រឡាបញ្ជី

[redacted]



Scanned by CamScanner